សូមជម្រាបសួរ! នេះជាការពិពណ៌នាទៅលើព្រឹត្តិការណ៍ដែលកើតឡើង ដែលពាក់ព័ន្ធទៅនឹងរដូវប្រាំង។ អញ្ចឹងនៅក្នុងប្រទេសកម្ពុជាគឺមានរដូវពីរ រដូវប្រាំង ហើយនិងរដូវវស្សា។ រដូវប្រាំងគឺជារដូវមួយដែលមានអាកាសធាតុក្តៅ ហើយស្ងួត ដោយសារមិនមានភ្លៀងធ្លាក់នោះទេ។ ហើយមានពេលខ្លះមានភ្លៀងធ្លាក់ដែរ យើងហៅថាភ្លៀងកក់ខែ។ អញ្ចឹងនៅក្នុងរដូវប្រាំង គឺកម្រនឹងមានភ្លៀងធ្លាក់ណាស់ ហើយអាកាសធាតុគឺក្តៅ។ ហើយនៅក្នុងរដូវប្រាំង ជាទូទៅ [...] បើយើងសង្កេតទៅលើមើលទឹកទន្លេ ដោយសារក្នុងរដូវទាំងពីរនេះគឺ វាធ្វើឲ្យមានផលប៉ះពាល់ទៅទឹកទន្លេដូចគ្នា។ នៅក្នុងរដូវវស្សា ធ្វើឲ្យទឹកទន្លេឡើងខ្លាំង ឡើងពៀបទៅនឹងមាត់ទន្លេ ហើយរដូវប្រាំង គឺទឹកទន្លេគឺស្រកចុះ។ អញ្ចឹងរដូវប្រាំងគឺទឹកទន្លេស្រកចុះ ហើយទឹកមិនសូវហូរខ្លាំងនោះទេ។ អញ្ចឹងទឹកអត់សូវហូរខ្លាំង[...] គឺទឹកទន្លេនឹង។ ហើយផ្ទះរបស់ខ្ញុំគឺស្ថិតនៅក្បែរមាត់ទន្លេមួយ ហៅថាទន្លេមេគង្គ គឺជាទន្លេដែលធំ ហើយហូរកាត់ចំនួន ៦ ប្រទេស។ ហើយទន្លេមេគង្គនេះគឺ នៅក្នុងរដូវប្រាំង គឺទឹកថ្លា ពាក្យថាថ្លា គឺមានន័យថាទឹកវាអត់មានដីល្អក់នោះទេ គឺទឹកថ្លា ហើយទឹកទន្លេមេគង្គ គឺក្នុងរដូវប្រាំងជាទូទៅ ទឹកនឹងគឺហូរដែរ តែហូរតិចៗ ហើយងាយស្រួល[ក្នុង ?]ការដែលយើងហែលលេង ដូចទឹកអាងអញ្ចឹង គឺអត់ហូរខ្លាំងនោះទេ ហើយមិនសូវមានគ្រោះថ្នាក់នោះដែរ។ អញ្ចឹងក្នុងការដែលយើងមុជទឹក ចង់ទៅហែល រៀនហែលទឹក មុជទឹក ឬក៏លេងសម្រាប់ក្មេងៗគឺ សុវត្ថិភាពល្អនៅក្នុងខែប្រាំង ដោយសារនៅក្នុងខែប្រាំងនេះ គឺទឹកទន្លេមេគង្គ គឺនឹងហើយ ហូរតិចៗ ហើយទឹកថ្លា គួរឲ្យចង់ហែល ហើយខ្ញុំចូលចិត្តហែលទឹកទន្លេមេគង្គខ្លាំងណាស់ ដោយសារផ្ទះរបស់ខ្ញុំគឺមិនឆ្ងាយពីទន្លេទេ គឺនៅក្បែរមាត់ទន្លេ ហើយផ្ទះរបស់ខ្ញុំគឺប្រហែលជា ពីរ បី នាទីតែប៉ុណ្ណោះពីមាត់ទន្លេ ហើយខ្ញុំតែងតែដើរទៅមុជទឹក ហើយនឹងហែលទឹកនៅក្នុងទន្លេមេគង្គ។ [...] ហើយខ្ញុំចាំបានថា អ្នកដែលបង្រៀនខ្ញុំហែលទឹកនោះគឺ ជីតារបស់ខ្ញុំ។ ជីតារបស់ខ្ញុំ ហើយជីតារបស់ខ្ញុំ គាត់គឺជាអ្នកដែលបង្រៀនខ្ញុំឲ្យហែលទឹក ពេលដែលខ្ញុំនៅតូចគឺគាត់បង្រៀនខ្ញុំ ឲ្យហែលទឹកនៅក្នុងទន្លេមេគង្គនេះ។ ហើយពេលដែលខ្ញុំធំឡើង គឺខ្ញុំចូលចិត្តទៅហែលទឹកនៅក្នុងទន្លេមេគង្គ ជាមួយនឹងមិត្តភក្តិខ្ញុំ [...] អ្នកនៅជិតខាង អ្នកនៅក្បែរផ្ទះហ្នឹង មិត្តភក្តិដែលនៅក្បែរផ្ទះ ឬក៏អ្នកជិតខាង ហើយនិងបងស្រីរបស់ខ្ញុំ គឺពេលថ្ងៃ បន្ទាប់ពីញ៉ាំបាយថ្ងៃត្រង់រួច ពេលថ្ងៃប្រហែលជាម៉ោង ពីរ ឬក៏ម៉ោង បី គឺយើងនាំគ្នាទៅហែលទឹកក្នុងទន្លេមេគង្គនេះ។ ហើយទឹកទន្លេមេគង្គគឺ ទឹកថ្លា ទឹកនឹង ដូចជាទឹកអាងអញ្ចឹង គឺទឹកថ្លា ហើយងាយនឹងហែល ហើយមិនមានជម្រៅជ្រៅនោះទេ គឺទឹកវាមានជម្រាល អញ្ចឹងគឺយើងអាចហែលបាន ហែលលេង ដូចជាលេងនៅខាងៗ ប្រសិនជាយើងទៅឆ្ងាយបន្តិច គឺទឹកជ្រៅ ហើយបើយើងនៅខាងៗក្បែរមាត់ច្រាំងគឺទឹករាក់។ ហើយខ្ញុំចូលចិត្តហែលនៅក្នុងទឹកទន្លេមេគង្គនេះ។

ហើយនេះគឺជាអ្វីមួយដែលខ្ញុំចូលចិត្តធ្វើនៅក្នុងរដូវប្រាំង គឺការហែលទឹកលេងនៅក្នុង

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

នៅក្នុងទន្លេមេគង្គជាមួយនឹងមិត្តភក្តិ ហើយនិងបងស្រី ហើយអ្នកដែលបង្រៀនខ្ញុំឲ្យហែលទឹក
គឺជីតារបស់ខ្ញុំ ដែលជាអ្នកបង្រៀនខ្ញុំឲ្យចេះហែលទឹកដំបូងគេ។
ឲ្យខ្ញុំចូលចិត្តហែលទឹកខ្លាំងណាស់នៅពេលថ្ងៃ ហើយជាពិសេសនៅក្នុងខែប្រាំងនេះឯងដោយសារ
ខែប្រាំងគឺ ទឹកទន្លេមេគង្គ គឺទឹកនឹង ហើយទឹកថ្លា ស្អាត ហើយងាយស្រួលក្នុងការហែលលេងដែរ។
ហើយខ្ញុំក៏សូមបញ្ចប់ការពិពណ៌នាទៅលើ រដូវប្រាំង
ហើយនឹងព្រឹត្តិការណ៍ដែលខ្ញុំចូលចិត្តធ្វើនៅក្នុងរដូវប្រាំង គឺការហែលទឹកនៅក្នុងទន្លេមេគង្គនេះ។
សូមអរគុណ។

Copyright © 2016 www.aakanee.com – This document and the corresponding illustration and recording are provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.